ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

នាពេលថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានទទួលនូវព័ត៌មានពីបណ្តាញសង្គម "Pheng Vannak News" ដែលបានសរសេរអត្ថបទពាក់ព័ន្ធនឹងសិទ្ធិអំណាចចាត់ចែងមុខរបរជំនួញជ្រូក មាន់ ទា គោ ក្របី និងបានប៉ះពាល់ដល់កិច្ចការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមជម្រាបជូនសាធារណជនបានជ្រាបដូចខាងក្រោម៖

១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមច្រានចោលនូវខ្លឹមសារទាំងស្រុងដែលបានចុះផ្សាយដោយបណ្តាញសង្គម "Pheng Vannak News" កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ដោយហេតុថាការផ្សព្វផ្សាយព័ត៌មាននេះមិនត្រឹមត្រូវទៅតាមសភាពការណ៍ពិតជាក់ស្តែងនោះឡើយ និងបានធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២-ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការពន្យល់ដល់សាធារណជនបានជ្រាបថា ការធ្វើអាជីវកម្មនាំចេញ នាំចូល និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមលក្ខខណ្ឌ នីតិវិធី និងបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។ រាល់ការស្នើសុំនាំចេញ នាំចូល និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ គឺចាំបាច់ត្រូវឆ្លងកាត់ការពិនិត្យ និងផ្តល់យោបល់ពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដែលជាសេនាធិការជំនាញបច្ចេកទេសរបស់ក្រសួង មុននឹងក្រសួងចេញលិខិតអនុញ្ញាត ពោលគឺមិនមានអ្នកណាម្នាក់ចាត់ចែងការងារនេះជំនួសមុខឱ្យអង្គភាពជំនាញបានឡើយ។

៣-ក្នុងគោលដៅពង្រឹងការងារគ្រប់គ្រងផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តការរឹតបន្តឹងវិធានការបច្ចេកទេស សំដៅការពារសុខភាពសាធារណៈ បង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ព្រមទាំងធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាព។

ព័ត៌មានដូចបានបញ្ជាក់ជូនខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសង្ឃឹមយ៉ាងមុតមាំថា បណ្តាញព័ត៌មាននានាក៏ដូចជាសាធារណជន មេត្តាជ្រាប និងសូមចូលរួមសហការឱ្យបានល្អជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ៩រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០២០
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726,128 / 726 129, Fax: (855) 23-217 320